(២៣៨) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ នោ វត រេ វត្តព្វេ បរិហាយតិ អរហា អរហត្តាតិ ។

(២៣៩) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ សតិប្បដ្ឋានា ភាវិតា ។ បេ ។ សម្មប្បធានា ភាវិតា ឥទ្ធិបាទា ភាវិតា ឥន្ទ្រិយា ភាវិតា ពលា ភាវិតា ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ បរិហាយតិ អរហា អរហត្តាតិ ។

លះទិដ្ឋិ លះវិចិកិច្ឆា លះថីនៈ លះឧទ្ធច្ចៈ លះអហិរិកៈ លះអនោត្តប្បៈ ដែលមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ដែលមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

(២៣៨) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

(២៣៩) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។ បេ ។ ចម្រើនសម្មប្បធាន ចម្រើនឥទ្ធិបាទ ចម្រើនឥន្ទ្រិយ ចម្រើនពលៈ ចម្រើនពោជ្ឈង្គឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

( ២៤០ ) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ ននុ អរហតោ ទោសប្បហានាយ ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ បរិហាយតិ អរហា អរហត្តាតិ ។

( ២៤១ ) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ ននុ អរហា វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ ឱហិតភារោ អនុប្ប-ត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុ-ត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ អព្វុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខំ តស្ស បរិញ្ញាតំ សមុទយោ បហីនោ និរោធោ សច្ឆិកតោ មគ្គោ ភាវិតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ

[៦៤០] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។ បេ ។ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គ ដើម្បីលះអនោត្តប្បៈ មានអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

[៦៤១] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះអរហន្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ មានមោហៈទៅប្រាសហើយ មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយ ដោយលំដាប់ មានភវសញ្ញោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះទ្វារ គឺអវិជ្ជាបើកហើយ មានគូទម្លាយហើយ មានសសរខឿនដកហើយ មិនមានគន្លឹះទ្វារ ជាព្រះអរិយៈ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិនប្រកបដោយកិលេស មានជ័យជំនះឈ្នះល្អហើយ ព្រះអរហន្តនោះ បានកំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ធម៌ដែលគួរត្រាស់ដឹង ព្រះអរហន្តនោះ បានត្រាស់ដឹងហើយ ធម៌ដែលគួរកំណត់ដឹង ព្រះអរហន្តនោះ បានកំណត់ដឹងហើយ

បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកាតន្តិ ។ អាមន្តា ។ ហញ្ចិ អរហា វិគតរាគោ វិគតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នោ វត រេ វត្តព្វេ បរិហាយតិ អរហា អរហត្តាតិ ។

(២៤២) បរិហាយតិ អរហា អរហត្តាតិ[1] ។ សមយវិមុត្តោ អរហា អរហត្តា បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តា ន បរិហាយតីតិ ។ សមយវិមុត្តោ អរហា អរហត្តា បរិហាយតីតិ ។ អាមន្តា ។ អសមយវិមុត្តោ អរហា អរហត្តា បរិហាយតីតិ ។ ន ហេវំ វត្តព្វេ ។ អសមយវិមុត្តោ អរហា អរហត្តា ន បរិហាយតីតិ ។ អាមន្តា ។ សមយវិមុត្តោ អរហា អរហត្តា ន បរិហាយតីតិ ។ ន ហេវំ វត្តព្វេ ។

(២៤៣) សមយវិមុត្តស្ស អរហតោ រាគោ បហីនោ បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ អសមយវិមុត្តស្ស អរហតោ រាគោ បហីនោ បរិហាយតិ អសមយវិមុត្តោ អរហា

---

១ ម. ឯត្ថន្តរេ អាមន្តាតិ ទិស្សតិ ។

ធម៌ដែលគួរលះ ព្រះអរហន្តនោះបានលះហើយ ធម៌ដែលគួរចម្រើន ព្រះអរហន្តនោះបានចម្រើនហើយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះបានធ្វើជាក់ច្បាស់ហើយឬ ។ អើ ។ បើព្រះអរហន្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។ បេ ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះដែរ ។

(២៤២) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ ព្រះអរហន្តជាសមយវិមុត្ត សាបសូន្យចាកអរហត្ត ព្រះអរហន្តជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ ព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអហត្តទេឬ ។ អើ ។ ព្រះអរហន្ត ជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។

(២៤៣) ព្រះអរហន្ត ជាសមយវិមុត្ត លះរាគៈ ហើយព្រះអរហន្តជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាអសមយវិមុត្ត លះរាគៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត

អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ សមយវិមុត្តស្ស អរហតោ ទោសោ បហីនោ ។បេ។ អនោត្តប្បំ បហីនំ បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ អសមយវិមុត្តស្ស អរហតោ ទោសោ បហីនោ ។បេ។ អនោត្តប្បំ បហីនំ បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ សមយវិមុត្តស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ អសមយវិមុត្តស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ សមយវិមុត្តស្ស អរហតោ រាគប្បហានាយ សតិប្បដ្ឋានា ភាវិតា ។បេ។ សម្មប្បធានា ភាវិតា ឥទ្ធិបាទា ភាវិតា ឥន្ទ្រិយា ភាវិតា ពលា ភាវិតា ពោជ្ឈង្គា ភាវិតា បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ អសមយវិមុត្តស្ស អរហតោ

សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត ជាសមយវិមុត្ត លះទោសៈ ។ បេ ។ លះអនោត្តប្បៈ ហើយព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាអសមយវិមុត្ត លះទោសៈ ។ បេ ។ លះអនោត្តប្បៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត ជាសមយវិមុត្ត ចំរើនមគ្គ ដើម្បីលះរាគៈ ហើយព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាអសមយវិមុត្ត ចំរើនមគ្គ ដើម្បីលះរាគៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត ជាសមយវិមុត្ត ចំរើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។ បេ ។ ចំរើនសម្មប្បធាន ចំរើនឥទ្ធិបាទ ចំរើនឥន្ទ្រិយ ចំរើនពលៈ ចំរើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាអសមយវិមុត្ត

កតប្បហានាយ សតិប្បដ្ឋានា ភាវិតា ។បេ។ ពោជ្ឈង្គា ភាវិតា បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ សមយវិមុត្តស្ស អរហតោ ទោសប្បហានាយ ។បេ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។បេ។ ពោជ្ឈង្គា ភាវិតា បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ អសមយវិមុត្តស្ស អរហតោ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។បេ។ ពោជ្ឈង្គា ភាវិតា បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។បេ។

( ២៤៤ ) សមយវិមុត្តោ អរហា វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ អព្ពុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ

ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត ជាសមយវិមុត្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។ បេ ។ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាអសមយវិមុត្ត ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(២៤៤) ព្រះអរហន្ត ជាសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ មានមោហៈទៅប្រាសហើយ មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយដោយលំដាប់ មានភពនិងសញ្ញោជនៈអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះទ្វារគឺអវិជ្ជាបើកហើយ មានគូទម្លាយហើយ មានសសរខឿនដកហើយ មិនមានគន្លឹះទ្វារ ជាព្រះអរិយៈ មានទង់ ដាក់ចុះហើយ មានភារៈ ដាក់ចុះហើយ

វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខំ តស្ស បរិញ្ញាតំ សមុទយោ បហីនោ និរោធោ សច្ឆិកតោ មគ្គោ ភាវិតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតំ បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ អសមយវិមុត្តោ អរហា វីតរាគោ វីតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤៨] អសមយវិមុត្តស្ស អរហតោ រាគោ បហីនោ ន បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ សមយវិមុត្តស្ស អរហតោ រាគោ បហីនោ ន បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ អសមយវិមុត្តស្ស អរហតោ ទោសោ បហីនោ ។ បេ ។ អនោត្តប្បំ

មិនប្រកបដោយកិលេស មានជ័យជំនះឈ្នះល្អហើយ ព្រះអរហន្តនោះ បានកំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចំរើននូវមគ្គសច្ច ធម៌ដែលគួរត្រាស់ដឹង ព្រះអរហន្តនោះ បានត្រាស់ដឹងហើយ ធម៌ដែលគួរកំណត់ដឹង ព្រះអរហន្តនោះ បានកំណត់ដឹងហើយ ធម៌ដែលគួរលះ ព្រះអរហន្តនោះ បានលះហើយ ធម៌ដែលគួរចំរើន ព្រះអរហន្តនោះ បានចំរើនហើយ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ព្រះអរហន្ត ជាសមយវិមុត្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត ជាអសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។ បេ ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហើយព្រះអរហន្ត ជាអសមយវិមុត្ត សាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(២៤៩) ព្រះអរហន្ត ជាអសមយវិមុត្ត លះរាគៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្ត ជាសមយវិមុត្ត លះរាគៈ ហើយព្រះអរហន្ត ជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត ជាអសមយវិមុត្ត លះទោសៈ ។ បេ ។ លះអនោត្តប្បៈ

បហីនំ ន បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ សមយវិមុត្តស្ស អរហតោ អនោត្តប្បំ បហីនំ ន បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ អសមយវិមុត្តស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ន បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ សមយវិមុត្តស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ន បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ អសមយវិមុត្តស្ស អរហតោ ទោសប្បហានាយ ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ន បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ សមយវិមុត្តស្ស អរហតោ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ន បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។

ហើយព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្ត ជាសមយវិមុត្ត លះអនោត្តប្បៈ ហើយព្រះអរហន្ត ជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត ជាអសមយវិមុត្ត ចំរើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចំរើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្ត ជាសមយ-វិមុត្ត ចំរើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចំរើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត ជាអសមយវិមុត្ត ចំរើនមគ្គ ដើម្បីលះទោសៈ ។ បេ ។ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចំរើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្ត ជាសមយវិមុត្ត ចំរើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចំរើនពោជ្ឈង្គៈ ហើយព្រះអរហន្ត ជាសមយ-វិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។

អសមយវិមុត្តោ អរហា វីតរាគោ វីតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ ន បរិហាយតិ អសមយវិមុត្តោ អរហា អរហត្តាតិ ។ អាមន្តា ។ សមយវិមុត្តោ អរហា វីតរាគោ វីតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ ន បរិហាយតិ សមយវិមុត្តោ អរហា អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៤៦) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ សារីបុត្តោ ថេរោ បរិហាយិត្ថ អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ មហាមោគ្គល្លានោ ថេរោ មហាកស្សបោ ថេរោ មហាកច្ចាយនោ ថេរោ មហាកោដ្ឋិកោ ថេរោ មហាបន្ថកោ ថេរោ បរិហាយិត្ថ អរហត្តាតិ ។ ន ហេវំ វត្តព្វេ ។ សារីបុត្តោ ថេរោ ន បរិហាយិត្ថ អរហត្តាតិ ។ អាមន្តា ។ ហញ្ចិ សារីបុត្តោ ថេរោ ន បរិហាយិត្ថ អរហត្តា តេន វត រេ វត្តព្វេ បរិហាយតិ អរហា អរហត្តាតិ ។ មហាមោគ្គល្លានោ ថេរោ ... មហាកស្សបោ ថេរោ ... មហាកច្ចាយនោ ថេរោ ...

ព្រះអរហន្ត ជាសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។ បេ ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហើយព្រះអរហន្ត ជាអសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ ព្រះអរហន្ត ជាសមយវិមុត្ត មានរាគៈទៅប្រាសហើយ មានទោសៈទៅប្រាសហើយ ។ បេ ។ ធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ព្រះអរហន្តនោះ បានធ្វើឲ្យជាក់ច្បាស់ហើយ ហើយព្រះអរហន្ត ជាសមយវិមុត្ត មិនសាបសូន្យចាកអរហត្តទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(២៤៦) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះសារីបុត្តត្ថេរ សាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះមហាមោគ្គល្លានត្ថេរ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិកត្ថេរ ព្រះមហាបណ្ឌកត្ថេរ សាបសូន្យចាកអរហត្តដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះសារីបុត្តត្ថេរ មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ បើព្រះសារីបុត្តត្ថេរ មិនសាបសូន្យចាកអរហត្តទេ ម្នាលអ្នកដ៏ចំរើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្តដូច្នេះទេ ។ ព្រះមហាមោគ្គល្លានត្ថេរ... ព្រះមហាកស្សបត្ថេរ... ព្រះមហាកច្ចាយនត្ថេរ...

មហាកោដ្ឋិកោ ថេរោ.. មហាបន្ថកោ ថេរោ ន បរិហាយិត្ថ អរហត្តាតិ ។ អាមន្តា ។ ហញ្ចិ មហាមោគ្គល្លានោ ថេរោ.. ។ បេ ។ មហាបន្ថកោ ថេរោ ន បរិហាយិត្ថ អរហត្តា នោ ច វត រេ វត្តព្វេ បរិហាយតិ អរហា អរហត្តាតិ ។

(២៤៧) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ឧច្ចាវចា ហិ បដិបទា សមណេន បកាសិតា

ន បារំ ទិគុណំ យន្តិ នយិទំ ឯកគុណំ មុតន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ បរិហាយតិ អរហា អរហត្តាតិ ។

(២៤៨) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ អត្ថិ ឆិន្នស្ស ឆេទិយន្តិ ។ ន ហេវំ វត្តព្វេ ។ អត្ថិ ឆិន្នស្ស ឆេទិយន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ព្រះមហាកោដ្ឋិកត្ថេរ ... ព្រះមហាបណ្ឋកត្ថេរ មិនសាបសូន្យចាកអរហត្តទេឬ ។ អើ ។ បើព្រះមហាមោគ្គល្លានត្ថេរ ... ។ បេ ។ ព្រះមហាបណ្ឋកត្ថេរ មិនសាបសូន្យចាកអរហត្តទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្តដូច្នេះទេ ។

(២៤៧) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ បានត្រាស់ថា

សេចក្តីប្រតិបត្តិខ្ពស់និងទាប ព្រះសមណៈ ប្រកាសហើយ
(សត្វទាំងឡាយ) មិនដល់នូវត្រើយ គឺព្រះនិព្វានពីរ
ដងទេ ត្រើយ គឺព្រះនិព្វាននេះ ពួកសត្វមិនដែលពាល់
ត្រូវអស់វារៈម្តងឡើយ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

(២៤៨) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ធម្មជាតតិចតួចដែលគេគប្បីកាត់ របស់ព្រះអរហន្តដែលមានកិលេសវដ្តៈកាត់ហើយ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ធម្មជាតតិចតួចដែលគេគប្បីកាត់ របស់ព្រះអរហន្ត ដែលមានកិលេស-វដ្តៈកាត់ហើយ មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ បានត្រាស់ថា

វីតតណ្ហោ អនាគារោ កិច្ចំ យស្ស ន វិជ្ជតិ
ឆិន្នស្ស ឆេតិយំ នត្ថិ ឱឃបាសោ សមូហតោតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អត្ថិ ឆិន្នស្ស ឆេតិយន្តិ ។

[២៤៩] បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ នត្ថិ កតស្ស បដិចយោតិ ។ ន ហេវំ វត្តព្វេ ។ អត្ថិ កតស្ស បដិចយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

តស្ស សម្មាវិមុត្តស្ស សន្តចិត្តស្ស ភិក្ខុនោ
កតស្ស បដិចយោ នត្ថិ ករណីយំ ន វិជ្ជតិ
សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ រូបា រសា សទ្ទា គន្ធា ផស្សា ច កេវលា

> កិច្ចនៃបុគ្គលណា មិនមាន ( បុគ្គលនោះ ) មានតណ្ហា
> ទៅប្រាសហើយ មិនមានសេចក្ដីប្រកាន់ទេ ធម្មជាតតិច
> តួចដែលគេគប្បីកាត់ របស់បុគ្គល ដែលមានកិលេសវដ្ដៈ
> កាត់ហើយ មិនមានឡើយ ( ព្រោះ ) បុគ្គលនោះ
> បានដកចោលហើយ នូវអន្ទង់និងអន្ទាក់ គឺកិលេស

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម្មជាតតិចតួចដែលគេគប្បីកាត់ របស់ព្រះអរហន្ត ដែលមានកិលេសវដ្ដៈកាត់ហើយ មានដូច្នេះទេ ។

( ២៤៩ ) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ការចំរើនមគ្គ ដែលបុគ្គលបានចំរើនរួចហើយ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ការចំរើនមគ្គ ដែលបុគ្គលបានចំរើនរួចហើយ មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ បានត្រាស់ថា

> កិច្ចអ្នកមានចិត្តរួចស្រឡះ អ្នកមានចិត្តស្ងប់រម្ងាប់នោះ រមែង
> មិនមានការចំរើនមគ្គ ដែលបានចំរើនរួចហើយទេ ទាំង
> កិច្ចដែលគួរធ្វើ ក៏មិនមានឡើយ ថ្មតាន់មួយដុំ រមែង
> មិនកំរើកញាប់ញ័រ ដោយខ្យល់ យ៉ាងណា រូប រស
> សំឡេង ក្លិន ផស្សៈទាំងអស់ ទាំងពួកធម៌ដែលគួរប្រាថ្នា

ឥដ្ឋា ធម្មា អនិដ្ឋា ច នប្បវេធេន្តិ តាទិនោ
ឋិតំ ចិត្តំ វិប្បមុត្តំ វយំ ចស្សានុបស្សតីតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អត្ថិ កតស្ស បដិចយោតិ ។

(២៤០) ន វត្តព្វំ បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមេ ភិក្ខវេ ធម្មា សមយវិមុត្តស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ កតមេ បញ្ច កម្មារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា យថា វិមុត្តំ ចិត្តំ ន បច្ចវេក្ខតិ ឥមេ ខោ ភិក្ខវេ បញ្ច ធម្មា សមយវិមុត្តស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បរិហាយតិ អរហា អរហត្តាតិ ។

និងមិនគួរប្រាថ្នា ក៏រមែងមិនញុំាងចិត្តដែលរួចស្រឡះ ជាចិត្តនឹងធឹង របស់តាទិបុគ្គល ឲ្យញាប់ញ័រ យ៉ាងនោះដែរ ម្យ៉ាងទៀត ( តាទិបុគ្គលនោះ ) ឃើញរឿយៗ នូវការសូន្យ នៃចិត្តនោះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ការចំរើនមគ្គ ដែលបុគ្គលបានចំរើនហើយ មានដូច្នេះទេ ។

[ ២៥០ ] អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្តទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសមយវិមុត្ត មានធម៌ ៥ នេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ធម៌ ៥ នោះ ដូចម្តេចខ្លះ សេចក្តីត្រេកអរ ក្នុងការងារ ១ សេចក្តីត្រេកអរក្នុងតិរច្ឆានកថា ១ សេចក្តីត្រេកអរក្នុងការដេកលក់ ១ សេចក្តីត្រេកអរក្នុងពួកបន ១ ភិក្ខុជាសមយវិមុត្តមិនពិចារណានូវចិត្តដែលរួចស្រឡះហើយ ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាសមយវិមុត្ត មានធម៌ទាំង ៥ នេះឯង ប្រព្រឹត្តដើម្បីសេចក្តីសាបសូន្យ ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ បើដូច្នោះ ព្រះអរហន្ត សាបសូន្យចាកអរហត្តដែរឬ ។

[២៨១] អត្ថិ អរហតោ កម្មារាមតាតិ ។ ន ហេវំ វត្តព្វេ ។ អត្ថិ អរហតោ កម្មារាមតាតិ ។ អាមន្តា ។ អត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ អត្ថិ អរហតោ ភស្សារាមតា អត្ថិ អរហតោ និទ្ទារាមតា អត្ថិ អរហតោ សង្គណិការាមតាតិ ។ ន ហេវំ វត្តព្វេ ។ អត្ថិ អរហតោ សង្គណិការាមតាតិ ។ អាមន្តា ។ អត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨២] បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ អរហា អរហត្តា បរិហាយមានោ កឹ បរិយុដ្ឋិតោ បរិហាយតីតិ ។ រាគបរិយុដ្ឋិតោ បរិហាយតីតិ ។ បរិយុដ្ឋានំ កឹ បដិច្ច ឧប្បជ្ជតីតិ ។ អនុសយំ បដិច្ច ឧប្បជ្ជតីតិ ។ អត្ថិ អរហតោ អនុសយាតិ ។

[២៥១] ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងការងារដៃវត្ថុ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងការងារវត្ថុ ។ អើ ។ ព្រះអរហន្ត មានរាគៈ កាមរាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ ដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងតិរច្ឆានកថា ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងការដេកលក់ ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងពួកបនវត្ថុ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ព្រះអរហន្ត មានសេចក្តីត្រេកអរក្នុងពួកបនវត្ថុ ។ អើ ។ ព្រះអរហន្ត មានរាគៈ កាមរាគៈ កាមរាគបរិយុដ្ឋាន កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[២៥២] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ ព្រះអរហន្ត កាលសាបសូន្យចាកអរហត្ត តើគ្របសង្កត់អ្វី ទើបបាន សាបសូន្យ ។ ព្រះអរហន្ត គ្របសង្កត់រាគៈ ទើបបានសាបសូន្យ ។ បរិយុដ្ឋានកិលេស អាស្រ័យ អ្វី ទើបកើតឡើងបាន ។ អាស្រ័យនូវ អនុស័យ ទើបកើតឡើងបាន ។ ព្រះអរហន្ត មានអនុស័យឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អរហតោ អនុសយាតិ ។ អាមន្តា ។ អត្ថិ អរហតោ កាមរាគានុសយោ បដិឃានុសយោ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ភវរាគានុសយោ អវិជ្ជានុសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសបរិយុដ្ឋិតោ បរិហាយតីតិ ។ បេ ។ មោហ-បរិយុដ្ឋិតោ បរិហាយតីតិ ។ បរិយុដ្ឋានំ កឹ បដិច្ច ឧប្បជ្ជតីតិ ។ អនុសយំ បដិច្ច ឧប្បជ្ជតីតិ ។ អត្ថិ អរហតោ អនុសយាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អរហតោ អនុសយាតិ ។ អាមន្តា ។ អត្ថិ អរហតោ កាមរាគានុសយោ ។ បេ ។ អ-វិជ្ជានុសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៤៣) បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ អរហតោ អរហត្តា បរិហាយមានស្ស កឹ ឧបចយំ គច្ឆតីតិ ។ រាគោ ឧបចយំ គច្ឆតីតិ ។ សក្កាយទិដ្ឋិ ឧបចយំ គច្ឆតីតិ ។ វិចិកិច្ឆា ឧប-ចយំ គច្ឆតីតិ ។ សីលព្វតបរាមាសោ ឧបចយំ

អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានអនុស័យឬ ។ អើ ។ ព្រះអរហន្ត មានកាមរាគានុស័យ បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ អវិជ្ជានុស័យឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ ព្រះអរហន្ត គ្របសង្កត់ទោសៈ ទើបបានសាបសូន្យឬ ។បេ។ គ្របសង្កត់មោហៈ ទើបបានសាបសូន្យឬ ។ បរិយុដ្ឋានកិលេស អាស្រ័យអ្វី ទើបកើតឡើងបាន ។ អាស្រ័យ អនុស័យ ទើបកើតឡើងបាន ។ ព្រះអរហន្ត មានអនុស័យឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។ ព្រះអរហន្ត មានអនុស័យឬ ។ អើ ។ ព្រះអរហន្ត មានកាមរាគានុស័យ ។បេ។ អវិជ្ជានុស័យឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

[២៥៣] ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។ កាលព្រះអរហន្ត សាបសូន្យចាកអរហត្ត តើអ្វីដល់នូវការផុះផាលឡើង ។ រាគៈដល់នូវការផុះផាលឡើង ។ សក្កាយទិដ្ឋិ ដល់នូវការផុះផាលឡើងឬ ។ វិចិកិច្ឆា ដល់នូវការផុះផាលឡើងឬ ។ សីលព្វតបរាមាសៈ

គច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសោ ឧបចយំ គច្ឆតីតិ ។ បេ ។ មោហោ ឧបចយំ គច្ឆតីតិ ។ សក្កាយទិដ្ឋិ ឧបចយំ គច្ឆតីតិ ។ វិចិកិច្ឆា ឧបចយំ គច្ឆតីតិ ។ សីលព្វតបរាមាសោ ឧបចយំ គច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៦] បរិហាយតិ អរហា អរហត្តាតិ ។ អាមន្តា ។ អរហា អាចិនតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា អបចិនតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា បជហតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា ឧបាទិយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា វិសិនេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា ឧស្សិនេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា វិធូបេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា សន្ធូបេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហា នេវាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ នោ

ដល់នូវការផុះផាលឡើងឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ
។ បេ ។ ទោសៈដល់នូវការផុះផាលឡើងឬ ។ បេ ។ មោហៈ
ដល់នូវការផុះផាលឡើងឬ ។ សក្កាយទិដ្ឋិ ដល់នូវការផុះផាលឡើង
ឬ ។ វិចិកិច្ឆា ដល់នូវការផុះផាលឡើងឬ ។ សីលព្វតបរាមាសៈ
ដល់នូវការផុះផាលឡើងឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(២៥៤) ព្រះអរហន្ត សាបសូន្យចាកអរហត្តឬ ។ អើ ។
ព្រះអរហន្តសន្សំឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។
ព្រះអរហន្ត ប្រាសចាកការសន្សំឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ
។ បេ ។ ព្រះអរហន្តលះបង់ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ
។ បេ ។ ព្រះអរហន្តប្រកាន់ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ
។ បេ ។ ព្រះអរហន្ត កកាយចេញឬ ។ អ្នកមិនគួរពោល យ៉ាង
នេះទេ ។ បេ ។ ព្រះអរហន្ត កៀរគរឬ ។ អ្នកមិនគួរពោល យ៉ាង
នេះទេ ។ បេ ។ ព្រះអរហន្ត កំចាត់ចេញឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ ព្រះអរហន្ត ប្រមូលមកឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្តមិនសន្សំ មិនប្រាសចាកការ
សន្សំ ឋិតនៅនឹង ព្រោះប្រាសចាកការសន្សំឬ ។ អើ ។ បើព្រះ
អរហន្តមិនសន្សំ មិនប្រាសចាកការសន្សំ ឋិតនៅនឹង ព្រោះ

## បរិហានិកថា

វត រេ វត្តព្ពេ បរិហាយតិ អរហា អរហត្តាតិ ។ ននុ អរហា នេវ បជហាតិ ន ឧបាទិយតិ បជ-ហិត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវ បជហាតិ ន ឧបាទិយតិ បជហិត្វា ឋិតោ នោ វត រេ វត្តព្ពេ បរិហាយតិ អរហា អរហត្តាតិ ។ ននុ អរហា នេវ វិសិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវ វិ-សិនេតិ ន ឧស្សិនេតិ វិសិនេត្វា ឋិតោ នោ វត រេ វត្តព្ពេ បរិហាយតិ អរហា អរហត្តាតិ ។ ននុ អរហា នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ-តិ ។ អាមន្តា ។ ហញ្ចិ អរហា នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា ឋិតោ នោ វត រេ វត្តព្ពេ បរិហាយតិ អរហា អរហត្តាតិ ។

បរិហានិកថា ។

ប្រាសចាកការសន្សំ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។ ក្រែងព្រះអរហន្ត មិនលះបង់ មិនប្រកាន់ ឋិតនៅនឹង ព្រោះលះបង់ឬ ។ អើ ។ បើព្រះអរហន្ត មិនលះបង់ មិនប្រកាន់ ឋិតនៅនឹង ព្រោះលះបង់ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។ ក្រែងព្រះអរហន្ត មិនកកាយចេញ មិនកៀគរ ឋិតនៅនឹង ព្រោះកកាយចេញឬ ។ អើ ។ បើព្រះអរហន្ត មិនកកាយចេញ មិនកៀគរ ឋិតនៅនឹង ព្រោះកកាយចេញ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។ ក្រែងព្រះអរហន្ត មិនកំចាត់ចេញ មិនប្រមូលមក ឋិតនៅនឹង ព្រោះកំចាត់ចេញឬ ។ អើ ។ បើព្រះអរហន្ត មិនកំចាត់ចេញ មិនប្រមូលមក ឋិតនៅនឹង ព្រោះកំចាត់ចេញ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត សាបសូន្យចាកអរហត្ត ដូច្នេះទេ ។

ចប់ បរិហានិកថា ។

# ព្រហ្មចរិយកថា

[២៥៥] នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ សន្តេ ទេវា ជឡា ឯឡមូគា អវិញ្ញូ ហត្ថសំវាចិកា ន បដិពលា សុភាសិតទុព្ភាសិតានំ អត្ថមញ្ញាតុំ សន្តេ ទេវា ន តុម្ហេ បសន្នា ន ធម្មេ បសន្នា ន សង្ឃេ បសន្នា ន ពុទ្ធំ ភគវន្តំ បយិរុបាសន្តិ ន ពុទ្ធំ ភគវន្តំ បញ្ហំ បុច្ឆន្តិ ន ពុទ្ធេន ភគវតា បញ្ហេ វិស្សជ្ជិតេ អត្តមនា សន្តេ ទេវា កម្មាវរណេន សមន្នាគតា កិលេសាវរណេន សមន្នាគតា វិបាកាវរណេន សមន្នាគតា អស្សទ្ធា អច្ឆន្ទិកា ទុប្បញ្ញា អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ សន្តេ ទេវា មាតុឃាតកា បិតុឃាតកា អរហន្តឃាតកា រុហិរុប្បាទកា សង្ឃភេទកា សន្តេ ទេវា បាណាតិបាតិនោ អទិន្នាទាយិនោ កាមេសុ មិច្ឆាចារិនោ មុសាវាទិនោ បិសុណាវាចា ផរុសាវាចា សម្ផប្បលាបិនោ អភិជ្ឈាលុនោ

# ព្រហ្មបរិយកថា

[២៥៥] ការប្រព្រឹត្តព្រហ្មចរិយធម៌(១) ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ ពួកទេវតាទាំងអស់ សុទ្ធតែល្ងង់ ខ្លៅ មិនចេះដឹង ប្រកបដោយការពោល ដោយដៃ (ដូចមនុស្សគ) មិនអាច ដើម្បីដឹងនូវសេចក្តីនៃសុភាសិតនិងទុព្ភាសិតបាន ពួកទេវតាទាំងអស់ មិនជ្រះថ្លាក្នុងព្រះពុទ្ធ មិនជ្រះថ្លាក្នុងព្រះធម៌ មិនជ្រះថ្លាក្នុងព្រះសង្ឃ មិនចូលទៅអង្គុយជិតព្រះពុទ្ធមានព្រះភាគ មិនសួរនូវប្រស្នានឹងព្រះពុទ្ធមានព្រះភាគ កាលបើប្រស្នាដែលព្រះពុទ្ធមានព្រះភាគដោះស្រាយហើយ មិនរីករាយ ពួកទេវតាទាំងអស់ ប្រកបដោយកម្មជារនាំង ប្រកបដោយកិលេសជារនាំង ប្រកបដោយវិបាកជារនាំង មិនមានសទ្ធា មិនមានឆន្ទៈ មិនមានប្រាជ្ញា មិនគួរចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកទេវតាទាំងអស់ ជាអ្នកសម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្ត ជាអ្នកធ្វើព្រះលោហិតរបស់ព្រះពុទ្ធ ឲ្យកើតឡើង ជាអ្នកបំបែកសង្ឃ ពួកទេវតាទាំងអស់ ជាអ្នកសម្លាប់សត្វ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកមានវាចាស៊កសៀត ជាអ្នកមានវាចាអាក្រក់ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមានអភិជ្ឈាជាប្រក្រតី

---

១ មាន ២ គឺចម្រើនមគ្គ ១ បព្វជ្ជា ១ ។ អដ្ឋកថា ។

បរិហានិកថា

ព្យាបន្នចិត្តា មិច្ឆាទិដ្ឋិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អត្ថិ លោកេ អជឡា អនេឡ-មូគា វិញ្ញូ ន ហត្ថសំវាចិកា បដិពលា សុភា-សិតទុព្ភាសិតានំ អត្ថមញ្ញាតុំ អត្ថិ លោកេ ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា ពុទ្ធំ ភគវន្តំ បយិរុបាសន្តិ ពុទ្ធំ ភគវន្តំ បញ្ហំ បុច្ឆន្តិ ពុទ្ធេន ភគវតា បញ្ហេ វិស្សជ្ជិតេ អត្តមនា ហោន្តិ អត្ថិ លោកេ ន កម្មាវរណេន សមន្នាគតា ន កិលេ-សាវរណេន សមន្នាគតា ន វិបាកាវរណេន ស-មន្នាគតា សទ្ធា ឆន្ទិកា បញ្ញវន្តោ ភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ អត្ថិ លោកេ ន មាតុឃាតកា ន បិតុឃាតកា ន អរហន្តឃា-តកា ន រុហិរុប្បាទកា ន សង្ឃភេទកា អត្ថិ លោកេ ន បាណាតិបាតិនោ ន អទិន្នាទាយិនោ ន កាមេសុ មិច្ឆាចារិនោ ន មុសាវាទិនោ ន បិសុ-ណាវាចា ន ផរុសវាចា ន សម្ផប្បលាបិនោ ន អភិជ្ឈាលុនោ អព្យាបន្នចិត្តា សម្មាទិដ្ឋិកាតិ ។

ជាអ្នកមានចិត្តព្យាបាទ ជាអ្នកមិច្ឆាទិដ្ឋិ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ក្រែងពួកទេវតា មិនល្ងង់ មិនខ្លៅ ចេះដឹង មិនប្រកបដោយការពោលដោយដៃ (ដូចមនុស្សគរទេ) អាចដើម្បីដឹងនូវសេចក្ដីនៃសុភាសិតនិងទុព្ភាសិតបាន ពួកទេវតា ជ្រះថ្លាក្នុងព្រះពុទ្ធ ជ្រះថ្លាក្នុងព្រះធម៌ ជ្រះថ្លាក្នុងព្រះសង្ឃ តែងចូលទៅអង្គុយជិតព្រះពុទ្ធមានព្រះភាគ សួរនូវប្រស្នានឹងព្រះពុទ្ធមានព្រះភាគ កាលបើប្រស្នា ដែលព្រះពុទ្ធមានព្រះភាគដោះស្រាយហើយ ក៏មានចិត្តរីករាយ ពួកទេវតា មិនប្រកបដោយកម្មជារនាំង មិនប្រកបដោយកិលេសជារនាំង មិនប្រកបដោយវិបាកជារនាំង មានសទ្ធា មានឆន្ទៈ មានបញ្ញា គួរដើម្បីចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ ពួកទេវតា មិនសម្លាប់មាតា មិនសម្លាប់បិតា មិនសម្លាប់ព្រះអរហន្ត មិនធ្វើព្រះលោហិតរបស់ព្រះពុទ្ធឲ្យកើតឡើង មិនបំបែកសង្ឃ ពួកទេវតា មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនពោលពាក្យកុហក មិនមានវាចាស៊កសៀត មិនមានវាចាអាក្រក់ មិនពោលពាក្យរោយរាយឥតប្រយោជន៍ មិនមានអភិជ្ឈាជាប្រក្រតី មានចិត្តមិនព្យាបាទ ជាសម្មាទិដ្ឋិ ។

អាមន្តា ។ ហញ្ចិ អត្ថិ ទេវា អសញ្ញា អនេឡមូគា វិញ្ញូ ន ហត្ថសំវាចិកា បដិពលា សុភាសិតទុព្ភាសិតានំ អត្ថមញ្ញាតុំ ។បេ។ អត្ថិ ទេវា ពុទ្ធេ បសន្នា ។ប។ សម្មាទិដ្ឋិកា តេ វត រេ វត្តព្វេ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។

(២៨៦) អត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ អត្ថិ តត្ថ បព្វជ្ជា មុណ្ឌិយំ កាសាវធារណា បត្តធារណា ទេវេសុ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ បច្ចេកសម្ពុទ្ធា ឧប្បជ្ជន្តិ សាវកយុគំ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(២៨៧) ទេវេសុ បព្វជ្ជា នត្ថីតិ ។ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យត្ថ អត្ថិ បព្វជ្ជា តត្ថេវ ព្រហ្មចរិយវាសោ យត្ថ នត្ថិ បព្វជ្ជា នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។បេ។ យត្ថ អត្ថិ បព្វជ្ជា តត្ថេវ

អើ ។ បើពួកទេវតា មិនល្ងង់ មិនខ្វៅ ចេះដឹង មិនប្រកបដោយការពោលដោយដៃ (ដូចជាមនុស្សគរ) អាចដើម្បីដឹងនូវសេចក្តីនៃសុភាសិតនិងទុព្ភាសិត ។ បេ ។ ពួកទេវតា ជ្រះថ្លាក្នុងព្រះពុទ្ធ ។ បេ ។ ជាសម្មាទិដ្ឋិ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការប្រព្រឹត្តិព្រហ្មចរិយធម៌ក្នុងទេវលោក មិនមាន ដូច្នេះឡើយ ។

(២៨៦) ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកទេវតា មានឬ ។ អើ ។ បព្វជ្ជា ភាពនៃបុគ្គលមានក្បាលត្រងោល ការទ្រទ្រង់សំពត់កាសាវៈ ការទ្រទ្រង់បាត្រ ក្នុងពួកទេវតានោះ មានឬ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ គូនៃសាវ័ក កើតក្នុងពួកទេវតា មានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(២៨៧) បព្វជ្ជា ក្នុងពួកទេវតា មិនមានទេឬ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ បព្វជ្ជា មានក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ បព្វជ្ជា មិនមានក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ បព្វជ្ជា មានក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ

### ព្រហ្មចរិយកថា

ព្រហ្មចរិយកោ យត្ថ នត្ថិ បព្វជ្ជា នត្ថិ តត្ថ ព្រហ្មចរិយកោតិ ។ អាមន្តា ។ យោ បព្វជ្ជតិ តស្សេវ ព្រហ្មចរិយកោ យោ ន បព្វជ្ជតិ នត្ថិ តស្ស ព្រហ្មចរិយកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៥៨) ទេវេសុ មុណ្ឌិយំ នត្ថីតិ ។ នត្ថិ ទេវេសុ ព្រហ្មចរិយកោតិ ។ អាមន្តា ។ យត្ថ អត្ថិ មុណ្ឌិយំ តត្ថេវ ព្រហ្មចរិយកោ យត្ថ នត្ថិ មុណ្ឌិយំ នត្ថិ តត្ថ ព្រហ្មចរិយកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ យត្ថ អត្ថិ មុណ្ឌិយំ តត្ថេវ ព្រហ្មចរិយកោ យត្ថ នត្ថិ មុណ្ឌិយំ នត្ថិ តត្ថ ព្រហ្មចរិយកោតិ ។ អាមន្តា ។ យោ មុណ្ឌោ ហោតិ តស្សេវ ព្រហ្មចរិយកោ យោ មុណ្ឌោ ន ហោតិ នត្ថិ តស្ស ព្រហ្មចរិយកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បញ្ញា មិនមានក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ បុគ្គលណាបួស ការប្រព្រឹត្តិព្រហ្មចរិយធម៌ របស់បុគ្គលនោះមាន បុគ្គលណា មិនបួស ការប្រព្រឹត្តិព្រហ្មចរិយធម៌ របស់បុគ្គលនោះមិនមានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(៦៥៨) ភាពនៃបុគ្គលមានក្បាលត្រងោល មិនមាន ក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ មិនមាន ក្នុងពួកទេវតាទេឬ ។ អើ ។ ភាពនៃបុគ្គលមានក្បាលត្រងោល មានក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ភាពនៃបុគ្គលមានក្បាលត្រងោល មិនមាន ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ភាពនៃបុគ្គលមានក្បាលត្រងោល មានក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មានក្នុងទីនោះដែរ ភាពនៃបុគ្គលមានក្បាលត្រងោល មិនមានក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អើ ។ បុគ្គលណា មានក្បាលត្រងោល ការប្រព្រឹត្តិព្រហ្មចរិយធម៌ របស់បុគ្គលនោះ ក៏មានដែរ បុគ្គលណា មិនមានក្បាលត្រងោល ការប្រព្រឹត្តិព្រហ្មចរិយធម៌ របស់បុគ្គលនោះ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[២៥៩] ទេវេសុ កាសាវធារណា នត្ថីតិ ។ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យត្ថ អត្ថិ កាសាវធារណា តត្ថេវ ព្រហ្មចរិយវាសោ យត្ថ នត្ថិ កាសាវធារណា នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ យត្ថ អត្ថិ កាសាវធារណា តត្ថេវ ព្រហ្មចរិយវាសោ យត្ថ នត្ថិ កាសាវធារណា នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យោ កាសាវំ ធារេតិ តស្សេវ ព្រហ្មចរិយវាសោ យោ កាសាវំ ន ធារេតិ នត្ថិ តស្ស ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦០] ទេវេសុ បត្តធារណា នត្ថីតិ ។ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យត្ថ អត្ថិ បត្តធារណា តត្ថេវ ព្រហ្មចរិយវាសោ យត្ថ

(៤៩៩) ការទ្រទ្រង់នូវសំពត់កាសាវៈ ក្នុងពួកទេវតា មិនមានទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ ការទ្រទ្រង់សំពត់កាសាវៈ មានក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ ការទ្រទ្រង់សំពត់កាសាវៈ មិនមាន ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ការទ្រទ្រង់សំពត់កាសាវៈ មាន ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ ការទ្រទ្រង់សំពត់កាសាវៈ មិនមាន ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អើ ។ បុគ្គលណា ទ្រទ្រង់សំពត់កាសាវៈ ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ មាន បុគ្គលណា មិនទ្រទ្រង់សំពត់កាសាវៈ ការប្រព្រឹត្តព្រហ្មចរិយធម៌ របស់បុគ្គលនោះ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

(៥០០) ការទ្រទ្រង់បាត្រ មិនមាន ក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មិនមាន ក្នុងពួកទេវតាឬ ។ អើ ។ ការទ្រទ្រង់បាត្រ មាន ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ

នត្ថិ បត្តធារណា នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ ន ហោតិ វត្តព្វេ ។ បេ ។ យត្ថ អត្ថិ បត្តធារណា តត្ថេវ ព្រហ្មចរិយវាសោ យត្ថ នត្ថិ បត្តធារណា នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យោ បត្តំ ធារេតិ តស្សេវ ព្រហ្មចរិយវាសោ យោ បត្តំ ន ធារេតិ នត្ថិ តស្ស ព្រហ្មចរិយវាសោតិ ។ ន ហោតិ វត្តព្វេ ។ បេ ។

( ២៦១ ) ទេវេសុ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តីតិ ។ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យត្ថ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ តត្ថេវ ព្រហ្មចរិយ-វាសោ យត្ថ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ ន ហោតិ វត្តព្វេ ។ បេ ។ យត្ថ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ តត្ថេវ ព្រហ្មចរិយ-វាសោ យត្ថ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ លុម្ពិនិយា ភគវា

ការទ្រទ្រង់បាត្រ មិនមាន ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ការទ្រទ្រង់បាត្រ មាន ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ ការទ្រទ្រង់បាត្រ មិនមាន ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អើ ។ បុគ្គលណា ទ្រទ្រង់បាត្រ ការប្រព្រឹត្តិព្រហ្មចរិយធម៌ របស់បុគ្គលនោះ មាន បុគ្គលណា មិនទ្រទ្រង់បាត្រ ការប្រព្រឹត្តិព្រហ្មចរិយធម៌ របស់បុគ្គលនោះ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៦៦១] ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនកើត ក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ មិនមាន ក្នុងពួកទេវតាទេឬ ។ អើ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ កើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មាននៅ ក្នុងទីនោះដែរ ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនកើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ កើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ ព្រះសម្មាសម្ពុទ្ធទាំងឡាយ មិនកើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមានក្នុងទីនោះដែរឬ ។ អើ ។ ព្រះមានព្រះភាគ ប្រសូតក្នុងលុម្ពិនីវ័ន

ជាតោ ពោធិយា មូលេ អភិសម្ពុទ្ធោ ពារាណសិយំ ភគវតា ធម្មចក្កំ បវត្តិតំ តត្ថ តត្ថេវ ព្រហ្មចរិយវាសោ នត្ថញ្ញត្រ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ២៦២ ] ទេវេសុ បច្ចេកសម្ពុទ្ធា នុប្បជ្ជន្តីតិ ។ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យត្ថ បច្ចេកសម្ពុទ្ធា ឧប្បជ្ជន្តិ តត្ថេវ ព្រហ្មចរិយវាសោ យត្ថ បច្ចេកសម្ពុទ្ធា នុប្បជ្ជន្តិ នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ យត្ថ បច្ចេកសម្ពុទ្ធា ឧប្បជ្ជន្តិ តត្ថេវ ព្រហ្មចរិយវាសោ យត្ថ បច្ចេកសម្ពុទ្ធា នុប្បជ្ជន្តិ នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ មជ្ឈិមេសុ ជនបទេសុ បច្ចេកសម្ពុទ្ធា ឧប្បជ្ជន្តិ តត្ថេវ ព្រហ្មចរិយវាសោ នត្ថញ្ញត្រ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

( ព្រៃរាំង ) ហើយត្រាស់ដឹងទៀបគល់ពោធិព្រឹក្ស ព្រះមានព្រះភាគ (អង្គនោះ) ទ្រង់ញុំាងធម្មចក្រ ឲ្យប្រព្រឹត្តទៅក្នុងក្រុងពារាណសី ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះ ៗ ដែរ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងទីដទៃ មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[ ២៦២ ] ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនកើត ក្នុងពួកទេវតា ទេឬ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនកើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនកើត ក្នុងទីណា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អើ ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើត ក្នុងមជ្ឈិមជនបទ ការប្រព្រឹត្តិព្រហ្មចរិយធម៌ មានតែក្នុងទីនោះឯង ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងទីឯទៀត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៣) ទេវេសុ សាវកាយុកំ ឧប្បជ្ជតីតិ ។ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ យត្ថ សាវកាយុកំ ឧប្បជ្ជតិ តត្ថេវ ព្រហ្មចរិយវាសោ យត្ថ សាវកាយុកំ ឧប្បជ្ជតិ នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ យត្ថ សាវកាយុកំ ឧប្បជ្ជតិ តត្ថេវ ព្រហ្មចរិយវាសោ យត្ថ សាវកាយុកំ ឧប្បជ្ជតិ នត្ថិ តត្ថ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ មគធេសុ សាវកាយុកំ ឧប្បន្នំ តត្ថេវ ព្រហ្មចរិយវាសោ នត្ថញ្ញត្រ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៤) អត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ សព្វទេវេសុ អត្ថិ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦៥) អត្ថិ មនុស្សេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ សព្វមនុស្សេសុ អត្ថិ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៣] គូនៃសាវ័ក មិនកើត ក្នុងពួកទេវតាទេឬ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមានទេឬ ។ អើ ។ គូនៃសាវ័ក កើត ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ គូនៃសាវ័ក មិនកើត ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ គូនៃសាវ័ក កើត ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ក្នុងទីនោះដែរ គូនៃសាវ័ក មិនកើត ក្នុងទីណា ការប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មិនមាន ក្នុងទីនោះដែរឬ ។ អើ ។ គូនៃសាវ័ក កើត ក្នុងដែនមគធៈ ការប្រព្រឹត្តព្រហ្មចរិយធម៌ មានតែក្នុងដែនមគធៈនោះឯង ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងទីឯទៀត មិនមានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[២៦៤] ការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងពួកទេវតា មានឬ ។ អើ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មាន ក្នុងពួកទេវតាទាំងអស់ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[២៦៥] ការប្រព្រឹត្តព្រហ្មចរិយធម៌ មាន ក្នុងពួកមនុស្សឬ ។ អើ ។ ការប្រព្រឹត្តព្រហ្មចរិយធម៌ មាន ក្នុងមនុស្សទាំងអស់ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[២៦៦] អត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ ទេវេសុ អត្ថិ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៧] អត្ថិ មនុស្សេសុ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ បច្ចន្តិមេសុ ជនបទេសុ អត្ថិ ព្រហ្មចរិយវាសោ មិលក្ខេសុ អវិញ្ញាតារេសុ យត្ថ នត្ថិ គតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៨] អត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថីតិ ។ អសញ្ញសត្តេសុ ទេវេសុ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថិ ព្រហ្មចរិយវាសោ សញ្ញសត្តេសុ[១] ទេវេសុ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថិ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទេវេសុ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថិ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ កត្ថចិ កត្ថ នត្ថីតិ ។ អសញ្ញសត្តេសុ ទេវេសុ នត្ថិ ព្រហ្មចរិយវាសោ សញ្ញសត្តេសុ[១] ទេវេសុ

---

១ ម. អសញ្ញសត្តេសុ ។

[៦៦៦] ការប្រព្រឹត្តិព្រហ្មចរិយធម៌ មាន ក្នុងពួកទេវតាឬ ។ អើ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ មាន ក្នុងពួកទេវតា ឈ្មោះថា អសញ្ញសត្វដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៦៦៧] ការប្រព្រឹត្តិព្រហ្មចរិយធម៌ មាន ក្នុងពួកមនុស្សឬ ។ អើ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខជន ជាអ្នកមិនចេះដឹង ក្នុងបច្ចន្តិមជនបទ ដែលជាជនបទមិនមានគតិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាទេ តើមានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៦៦៨] ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកទេវតា មានឬ ។ ប្រទេសដែលពួកទេវតាប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ប្រទេសដែលពួកទេវតាមិនប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានឬ ។ ទេវតាជាន់អសញ្ញសត្វ មានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះ ពួកទេវតាជាន់សញ្ញសត្វ មានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ក្នុងពួកទេវតា មានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះឬ ។ អើ ។ ចុះមានក្នុងទីណា មិនមានក្នុងទីណា ។ ទេវតាជាន់អសញ្ញសត្វ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ ទេវតាជាន់សញ្ញសត្វ

អត្ថិ ព្រហ្មចរិយវាសោតិ ។ អសញ្ញសត្តេសុ ទេវេសុ នត្ថិ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ សញ្ញសត្តេសុ(១) ទេវេសុ នត្ថិ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ សញ្ញសត្តេសុ(១) ទេវេសុ អត្ថិ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ ទេវេសុ អត្ថិ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៩] អត្ថិ មនុស្សេសុ ព្រហ្មចរិយវាសោតិ ។ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថីតិ ។ បច្ចន្តិមេសុ ជនបទេសុ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថិ ព្រហ្មចរិយវាសោ មិលក្ខូសុ អវិញ្ញាតារេសុ យត្ថ នត្ថិ គតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ មជ្ឈិមេសុ ជនបទេសុ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថិ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។

[២៧០] មនុស្សេសុ អត្ថិ យត្ថ អត្ថិ អត្ថិ យត្ថ នត្ថិ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ កត្ថត្ថិ កត្ថ នត្ថីតិ ។ បច្ចន្តិមេសុ ជនបទេសុ នត្ថិ ព្រហ្មចរិយវាសោ មិលក្ខូសុ អវិញ្ញាតារេសុ យត្ថ នត្ថិ គតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ

១ ម. អសញ្ញសត្តេសុ ។

មានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ ទេវតាជាន់អសញ្ញសត្វ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ អើ ។ ទេវតាជាន់សញ្ញសត្វ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ទេវតាជាន់សញ្ញសត្វ មានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ អើ ។ ទេវតាជាន់អសញ្ញសត្វ មានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៦៦៩] ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកមនុស្ស មានឬ ។ ប្រទេសដែលពួកមនុស្ស ប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មាន ប្រទេសដែលពួកមនុស្ស មិនប្រព្រឹត្តព្រហ្មចរិយធម៌ ក៏មានឬ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខជន ជាអ្នកមិនចេះដឹង មិនមានក្នុងបច្ចន្តិមជនបទ ដែលជាជនបទមានគតិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា មួយទៀត ក្នុងមជ្ឈិមជនបទ មានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។

[៦៧០] ក្នុងពួកមនុស្ស មានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ខ្លះឬ ។ អើ ។ ចុះមានក្នុងទីណា មិនមានក្នុងទីណា ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខជន ជាអ្នកមិនចេះដឹង មិនមានក្នុងបច្ចន្តិមជនបទ ដែលជាជនបទមិនមានគតិរបស់ពួកភិក្ខុ ភិក្ខុនី

ឧបាសិកានំ មជ្ឈិមេសុ ជនបទេសុ អត្ថិ ព្រហ្ម-
ចរិយវាសោតិ ។ បច្ចន្តិមេសុ ជនបទេសុ នត្ថិ ព្រហ្ម-
ចរិយវាសោតិ មិលក្ខេសុ អវិញ្ញាតារេសុ យត្ថ នត្ថិ
គតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកា-
នន្តិ ។ អាមន្តា ។ មជ្ឈិមេសុ ជនបទេសុ នត្ថិ
ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ មជ្ឈិមេសុ
ជនបទេសុ អត្ថិ ព្រហ្មចរិយវាសោតិ ។ អាមន្តា ។
បច្ចន្តិមេសុ ជនបទេសុ អត្ថិ ព្រហ្មចរិយវាសោ មិ-
លក្ខេសុ អវិញ្ញាតារេសុ យត្ថ នត្ថិ គតិ ភិក្ខូនំ
ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

[៦៧៣] អត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។
អាមន្តា ។ ននុ វុត្តំ ភគវតា តីហិ ភិក្ខវេ ឋានេហិ
ជម្ពុទីបកា មនុស្សា ឧត្តរកុរុកេ ច មនុស្សេ
អធិគ្គណ្ហន្តិ ទេវេ ច តាវតឹសេ ។ កតមេហិ តីហិ ។
សូរា សតិមន្តោ ឥធ ព្រហ្មចរិយវាសោតិ អត្ថេវ
សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ នត្ថិ ទេវេសុ
ព្រហ្មចរិយវាសោតិ ។ សាវត្ថិយំ វុត្តំ ភគវតា ឥធ

ឧបាសក ឧបាសិកា ក្នុងមជ្ឈិមជនបទ មានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខជន ជាអ្នកមិនចេះដឹងមិនខាន ក្នុងបច្ចន្តិមជនបទ ដែលជាជនបទមិនមានគតិ របស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឬ ។ អើ ។ ក្នុងមជ្ឈិមជនបទ មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ ក្នុងមជ្ឈិមជនបទ មានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ អើ ។ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកមិលក្ខជន ជាអ្នកមិនចេះដឹង មានក្នុងបច្ចន្តិមជនបទ ដែលជាជនបទមានគតិ របស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[២៧១] ក្នុងពួកទេវតា មានការប្រព្រឹត្តិព្រហ្មចរិយធម៌ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សនៅក្នុងជម្ពូទ្វីប គ្របសង្កត់ នូវពួកមនុស្សនៅក្នុងឧត្តរកុរុទ្វីបផង នូវពួកទេវតាជាន់តាវត្តឹង្សផង ដោយហេតុ ៣ យ៉ាង ។ ហេតុទាំង ៣ នោះ តើដូចម្តេច ។ ក្នុងជម្ពូទ្វីបនេះ ពួកមនុស្សជាអ្នកក្លៀវក្លា ១ មានសតិ ១ ការប្រព្រឹត្តិព្រហ្មចរិយធម៌ ១ ពាក្យដូច្នេះ មានក្នុងព្រះសូត្រពិតឬ ។ អើ ។ បើដូច្នោះ ក្នុងពួកទេវតា មិនមានការប្រព្រឹត្តិព្រហ្មចរិយធម៌ទេឬ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ក្នុងក្រុងសាវត្ថីថា ការប្រព្រឹត្តិ

## ព្រហ្មចរិយកថា

ព្រហ្មចរិយវាសោតិ ។ អាមន្តា ។ សាវត្ថិយញ្ញេវ ព្រហ្មចរិយវាសោ នត្ថញ្ញត្រ ព្រហ្មចរិយវាសោតិ ។ ន ហេវំ វត្តព្វេ ។ អនាគាមិស្ស បុគ្គលស្ស បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ឥតោ ចុតស្ស តត្ថ ឧប្បន្នស្ស កុហឹ ជលុប្បត្តីតិ ។ តត្ថេវ ។ ហញ្ចិ អនាគាមិស្ស បុគ្គលស្ស បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ឥតោ ចុតស្ស តត្ថ ឧប្បន្នស្ស តហឹ ជលុប្បត្តិ នោ វត រេ វត្តព្វេ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អនាគាមិស្ស បុគ្គលស្ស បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ឥតោ ចុតស្ស តត្ថ ឧប្បន្នស្ស កុហឹ ភារោហរណំ កុហឹ ទុក្ខបរិញ្ញាតំ កុហឹ កិលេសប្បហានំ កុហឹ និរោធសច្ឆិកិរិយា កុហឹ អកុប្បប្បដិវេធោតិ ។ តត្ថេវ ។

# ព្រហ្មចរិយកថា

ព្រហ្មចរិយធម៌ មាន ក្នុងក្រុងសាវត្ថីនេះ ដូច្នេះមែនឬ ។ អើ ។ ចុះការប្រព្រឹត្តព្រហ្មចរិយធម៌ មាន ក្នុងក្រុងសាវត្ថីតែប៉ុណ្ណោះ ក្នុងទីឯទៀត មិនមានការប្រព្រឹត្តព្រហ្មចរិយធម៌ទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ អនាគាមិបុគ្គល បានលះសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈ ជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះ ទៅកើតក្នុងជាន់សុទ្ធាវាសនោះ ចុះការកើតឡើងនៃផល ក្នុងទីណា ។ ការកើតឡើងនៃផល ក្នុងសុទ្ធាវាសនោះឯង ។ បើអនាគាមិបុគ្គល បានលះសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈ ជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើតក្នុងជាន់សុទ្ធាវាសនោះ ការកើតឡើងនៃផល ក៏ក្នុងសុទ្ធាវាសនោះឯង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការប្រព្រឹត្តព្រហ្មចរិយធម៌មិនមាន ក្នុងពួកទេវតា ដូច្នេះទេ ។ អនាគាមិបុគ្គល បានលះសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈ ជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើតក្នុងជាន់សុទ្ធាវាសនោះ ចុះការដាក់ចុះនូវភារៈក្នុងទីណា ការកំណត់ដឹងនូវទុក្ខក្នុងទីណា ការលះកិលេសក្នុងទីណា ការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ក្នុងទីណា ការចាក់ធ្លុះនូវធម៌មិនកំរើកក្នុងទីណា ។ ក្នុងសុទ្ធាវាសនោះឯង ។

ហញ្ចិ អនាគាមិស្ស បុគ្គលស្ស បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ឥតោ ចុតស្ស តត្ថ ឧបបន្នស្ស តេហិ អកុប្បប្បដិវេធោ នោ វត រេ វត្តព្វេ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ អនាគាមិស្ស បុគ្គលស្ស បញ្ចោរម្ភាគិយានិ សញ្ញោជនានិ បហីនានិ បញ្ចុទ្ធម្ភាគិយានិ សញ្ញោជនានិ អប្បហីនានិ ឥតោ ចុតស្ស តត្ថ ឧបបន្នស្ស តេហិ ផលុប្បត្តិ តេហិ ភារោហរណំ តេហិ ទុក្ខបរិញ្ញាតំ តេហិ កិលេសប្បហានំ តេហិ និរោធសច្ឆិកិរិយា តេហិ អកុប្បប្បដិវេធោ កោនជ្ជេន វទេសិ នត្ថិ ទេវេសុ ព្រហ្មចរិយវាសោតិ ។ ហន្ទ ហិ អនាគាមី បុគ្គលោ ឥធ ភាវេត្វា មគ្គំ តត្ថ ផលំ សច្ឆិករោតិ ។

បើអនាគាមិបុគ្គល បានលះសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈ ជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើត ក្នុងជាន់សុទ្ធាវាសនោះ ការត្រាស់ដឹងនូវធម៌មិនកម្រើក ក្នុងជាន់សុទ្ធាវាសនោះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការប្រព្រឹត្តិព្រហ្មចរិយធម៌ មិនមាន ក្នុងពួកទេវតា ដូច្នេះទេ ។ អនាគាមិបុគ្គល បានលះសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ មិនទាន់លះសញ្ញោជនៈ ជាចំណែកខាងលើ ៥ លុះច្យុតចាកអត្តភាពនេះទៅ បានទៅកើត ក្នុងជាន់សុទ្ធាវាសនោះ ការកើតឡើងនៃផល ក៏ក្នុងទីនោះ ការដាក់ចុះនូវភារៈ ក្នុងទីនោះ ការកំណត់ដឹងនូវទុក្ខ ក្នុងទីនោះ ការលះកិលេស ក្នុងទីនោះ ការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ក្នុងទីនោះ ការចាក់ធ្លុះនូវធម៌មិនកម្រើក ក្នុងទីនោះ អ្នកនិយាយថា ការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងពួកទេវតា មិនមាន ដូច្នេះ តើដោយសេចក្ដីដូចម្ដេច ។ បើដូច្នោះមានតែ អនាគាមិ-បុគ្គល មានមគ្គចម្រើនហើយ ក្នុងមនុស្សលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះ ។

(២៧២) អនាគាមី បុគ្គលោ ន ច ភាវិតេន មគ្គេន តត្ថ ផលំ សច្ឆិករោតីតិ ។ អាមន្តា ។ សោតាបន្នោ បុគ្គលោ តត្ថ ភាវិតេន មគ្គេន ន ច ផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាគាមី បុគ្គលោ ន ច ភាវិតេន មគ្គេន តត្ថ ផលំ សច្ឆិករោតីតិ ។ អាមន្តា ។ សកទាគាមី បុគ្គលោ ន ច បរិនិព្វាយិបុគ្គលោ តត្ថ ភាវិតេន មគ្គេន ន ច ផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតាបន្នោ បុគ្គលោ ន ច ភាវិតេន មគ្គេន ន ច ផលំ សច្ឆិករោតីតិ ។ អាមន្តា ។ អនាគាមី បុគ្គលោ តត្ថ ភាវិតេន មគ្គេន តត្ថ ផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមី បុគ្គលោ ន ច បរិនិព្វាយិបុគ្គលោ ន ច ភាវិតេន មគ្គេន ន ច ផលំ សច្ឆិករោតីតិ ។ អាមន្តា ។ អនាគាមី បុគ្គលោ តត្ថ ភាវិតេន មគ្គេន តត្ថ ផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧៦] អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ សោតាបន្នបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងមនុស្សលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ សកទាគាមិបុគ្គល ជាបុគ្គលបរិនិព្វាន ក្នុងលោកនេះ មានមគ្គចម្រើនហើយ ក្នុងលោកនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ សោតាបន្នបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អើ ។ អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងជាន់សុទ្ធាវាសនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ សកទាគាមិបុគ្គល ជាបុគ្គលបរិនិព្វាន ក្នុងលោកនេះ មានមគ្គចម្រើនហើយ ក្នុងលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងលោកនេះឬ ។ អើ ។ អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងជាន់សុទ្ធាវាសនោះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

( ២៧៣ ) ឥធ វិហាយនិដ្ឋស្ស បុគ្គលស្ស មគ្គោ ច ភាវិយតិ ន ច កិលេសា បហីយន្តិតិ ។ អាមន្តា ។ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស មគ្គោ ច ភាវិយតិ ន ច កិលេសា បហីយន្តិតិ ។ ន ហេវំ វត្តព្វេ ។បេ។ ឥធ វិហាយនិដ្ឋស្ស បុគ្គលស្ស មគ្គោ ច ភាវិយតិ ន ច កិលេសា បហីយន្តិតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស ។បេ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស មគ្គោ ច ភាវិយតិ ន ច កិលេសា បហីយន្តិតិ ។ ន ហេវំ វត្តព្វេ ។បេ។

( ២៧៤ ) សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អបុព្វំ អចរិមំ មគ្គោ ច ភាវិយតិ កិលេសា ច បហីយន្តិតិ ។ អាមន្តា ។ ឥធ វិហាយនិដ្ឋស្ស បុគ្គលស្ស អបុព្វំ អចរិមំ មគ្គោ ច ភាវិយតិ កិលេសា ច បហីយន្តិតិ ។ ន ហេវំ វត្តព្វេ ។បេ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស ។បេ។

[ ២៧៣ ] បុគ្គល ដែលសម្រេចដោយការលះ កន្លែលោកនេះ គ្រាន់តែចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អើ ។ បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល គ្រាន់តែចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ បុគ្គលសម្រេចដោយការលះ កន្លែលោកនេះ គ្រាន់តែចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អើ ។ បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ។ បេ ។ បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត គ្រាន់តែចម្រើនមគ្គ តែមិនទាន់លះកិលេសឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[ ២៧៤ ] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អើ ។ បុគ្គលសម្រេចដោយការលះ កន្លែលោកនេះ ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ។ បេ ។

អរហត្តផលសច្ចិកិរិយាយ បដិបន្នស្ស បុគ្គលស្ស អប្បត្តំ អធិគមិ មគ្គោ ច ភាវិយតិ កិលេសា ច បហីយន្តីតិ ។ អាមន្តា ។ ននុ វិហាយនិដ្ឋស្ស បុគ្គលស្ស អប្បត្តំ អធិគមិ មគ្គោ ច ភាវិយតិ កិលេសា ច បហីយន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៧៥) អនាគាមី បុគ្គលោ កតករណីយោ ភាវិតភាវនោ តត្ថ ឧបបជ្ជតីតិ ។ អាមន្តា ។ អរហា ឧបបជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា ឧបបជ្ជតីតិ ។ អាមន្តា ។ អត្ថិ អរហតោ បុនព្ភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អរហតោ បុនព្ភវោតិ ។ អាមន្តា ។ អរហា ភវេន ភវំ គច្ឆតិ គតិយា គតឹ គច្ឆតិ សំសារេន សំសារំ គច្ឆតិ ឧបបត្តិយា ឧបបត្តឹ គច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៧៦) អនាគាមី បុគ្គលោ កតករណីយោ ភាវិតភាវនោ អនោហដភារោ តត្ថ ឧបបជ្ជតីតិ ។ អាមន្តា ។ ភារោហារណាយ បុន មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បុគ្គលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អើ ។ បុគ្គលសម្រេចដោយការលះក្នុងលោកនេះ ចម្រើនមគ្គផង លះកិលេសផង ដំណាលគ្នាឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

( ២៧៥ ) អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ កើតឡើង ក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ ព្រះអរហន្ត កើតទៀតដែរឬ ។ អ្នកមិនគួរពោល យ៉ាងណានេះទេ ។ បេ ។ ព្រះអរហន្ត កើតទៀតឬ ។ អើ ។ ភពថ្មីនៃព្រះអរហន្ត មានឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ភពថ្មីនៃព្រះអរហន្ត មានឬ ។ អើ ។ ព្រះអរហន្ត ទៅកាន់ភពដោយភព ទៅកាន់គតិដោយគតិ ទៅកាន់សំសារដោយសំសារ ទៅកាន់ឧបបត្តិដោយឧបបត្តិឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

( ២៧៦ ) អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានភារៈមិនទាន់ដាក់ចុះ ទៅកើត ក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ អនាគាមិបុគ្គល ចម្រើនមគ្គទៀត ដើម្បីដាក់ចុះនូវភារៈឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[២៧៧] អនាគាមី បុគ្គលោ កតករណីយោ ភាវិតភាវនោ អបរិញ្ញាតទុក្ខោ អប្បហីនក្កិលេសោ អសច្ឆិកតនិរោធោ អប្បដិវិទ្ធាកុប្បោ តត្ថ ឧបបជ្ជតីតិ ។ អាមន្តា ។ អកុប្បប្បដិវេធាយ បុន មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧៨] អនាគាមី បុគ្គលោ កតករណីយោ ភាវិតភាវនោ អនោហដភារោ តត្ថ ឧបបជ្ជតីតិ ន ច ភារោហរណាយ បុន មគ្គំ ភាវេតីតិ ។ អាមន្តា ។ អនោហដភារោ ច តត្ថ បរិនិព្វាយតិ ។ ន ហេវំ វត្តព្វេ ។ អនាគាមី បុគ្គលោ កតករណីយោ ភាវិតភាវនោ អបរិញ្ញាតទុក្ខោ អប្បហីនក្កិលេសោ អសច្ឆិកតនិរោធោ អប្បដិវិទ្ធាកុប្បោ តត្ថ ឧបបជ្ជតិ ន ច អកុប្បប្បដិវេធាយ បុន មគ្គំ ភាវេតីតិ ។ អាមន្តា ។ អប្បដិវិទ្ធាកុប្បោ ច តត្ថ បរិនិព្វាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[ ២៧៧ ] អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានទុក្ខមិនទាន់កំណត់ដឹង មានកិលេសមិនទាន់លះ មាននិរោធ មិនទាន់ធ្វើឲ្យជាក់ច្បាស់ មានអកុប្បធម៌ មិនទាន់ចាក់ធ្លុះ រមែងកើតឡើង ក្នុងជាន់សុទ្ធាវាសនោះឬ ។ អើ ។ អនាគាមិបុគ្គល ចម្រើនមគ្គទៀត ដើម្បីចាក់ធ្លុះ នូវអកុប្បធម៌ឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[ ២៧៨ ] អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានភារៈមិនទាន់ដាក់ចុះ កើតឡើង ក្នុងជាន់សុទ្ធាវាសនោះ តែមិនទាន់ចម្រើនមគ្គទៀត ដើម្បីដាក់ចុះនូវភារៈទេឬ ។ អើ ។ ចុះអនាគាមិបុគ្គល មានភារៈមិនទាន់ដាក់ចុះ តើបរិនិព្វាន ក្នុងជាន់សុទ្ធាវាសនោះឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ អនាគាមិបុគ្គល មានករណីយកិច្ចធ្វើហើយ មានភាវនាអប់រំហើយ តែមានទុក្ខមិនទាន់កំណត់ដឹង មានកិលេសមិនទាន់លះ មាននិរោធ មិនទាន់ធ្វើឲ្យជាក់ច្បាស់ មានអកុប្បធម៌ មិនទាន់ចាក់ធ្លុះ រមែងទៅកើត ក្នុងជាន់សុទ្ធាវាសនោះ តែមិនបានចម្រើនមគ្គទៀត ដើម្បីត្រាស់ដឹងនូវអកុប្បធម៌ឬ ។ អើ ។ ចុះអនាគាមិបុគ្គល មានអកុប្បធម៌ មិនទាន់ត្រាស់ដឹង តើបរិនិព្វាន ក្នុងជាន់សុទ្ធាវាសនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

យថា មិគោ សល្លេន វិទ្ធោ ទូរម្បិ គន្ត្វា កាលំ ករោតិ ឯវមេវ អនាគាមី បុគ្គលោ ឥធ ភាវិតេន មគ្គេន តត្ថ ផលំ សច្ឆិករោតីតិ ។ យថា មិគោ សល្លេន វិទ្ធោ ទូរម្បិ គន្ត្វា សសល្លោវ កាលំ ករោតិ ឯវមេវ អនាគាមី បុគ្គលោ ឥធ ភាវិតេន មគ្គេន តត្ថ សសល្លោវ បរិនិព្វាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ព្រហ្មចរិយកថា ។

---

# ឱធិសោកថា

(២៧៩) ឱធិសោធិសោ កិលេសេ ជហាតីតិ ។ អាមន្តា ។ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខទស្សនេន កឹ ជហាតីតិ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ តទេកដ្ឋេ ច កិលេសេ ឯកទេសេ ជហាតីតិ ។ ឯកទេសំ សោតាបន្នោ ឯកទេសំ ន សោតាបន្នោ ឯកទេសំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា

សត្វម្រឹគ ដែលត្រូវសរមុត បោលទៅកាន់ទីឆ្ងាយ ហើយស្លាប់ទៅយ៉ាងណា អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងមនុស្សលោកនេះ ធ្វើឲ្យជាក់ច្បាស់នូវផល ក្នុងជាន់សុទ្ធាវាសនោះ ក៏យ៉ាងនេះដែរ ។ សត្វម្រឹគ ដែលត្រូវសរមុត បោលទៅកាន់ទីឆ្ងាយ ហើយស្លាប់ទាំងសរ យ៉ាងណា អនាគាមិបុគ្គល មានមគ្គចម្រើនហើយ ក្នុងលោកនេះ ហើយបរិនិព្វាន ក្នុងជាន់សុទ្ធាវាស ដូចជាម្រឹគស្លាប់ទាំងសរ យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។បេ។

ចប់ ព្រហ្មចរិយកថា ។

---

# ឱធិសោកថា

(២៧៩) បុគ្គលលះកិលេស ដោយចំណែក ៗ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល តើលះអ្វី ដោយការឃើញនូវទុក្ខ ។ លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងកិលេស ដែលជាចំណែកមួយ តាំងនៅក្នុងទីជាមួយនឹងសក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈនោះ ។ សោតាបន្នបុគ្គល ចំណែកមួយ មិនមែនសោតាបន្នបុគ្គល ចំណែកមួយ បុគ្គលដល់នូវសោតាបត្តិផល ដែលបានចំពោះ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវ ដោយនាមកាយ ចំណែកមួយ

